ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ ....០៨៦/២១............**ក.ប**/ប្រ.ក.ស.វិ.ក

ប្រកាស
ស្តីពី
លក្ខណវិនិច្ឆ័យក្នុងការកំណត់ និងការចុះបញ្ជិកាទទួលស្គាល់អ្នកវាយតម្លៃសមត្ថភាព

រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
និងជាប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនុក្រ/បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២២ អនក្រ.បក ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- បានឃើញប្រកាសលេខ៤៥៤ ក.ប/ប្រ.ក.គ.យ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តប្រព័ន្ធ និងគោលនយោបាយស្តីពីការវាយតម្លៃសមត្ថភាព និងការផ្តល់គុណវុឌ្ឍិ និងគោលនយោបាយស្តីពីការចុះកម្មសិក្សា
- យោងស្មារតីអង្គប្រជុំគណៈកម្មាធិការជាតិបណ្តុះបណ្តាល នាថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០។

សម្រេច

ប្រការ១.-

ប្រកាសនេះមានគោលបំណងបង្កើតលក្ខណវិនិច្ឆ័យក្នុងការកំណត់ និងការចុះបញ្ជិកាទទួលស្គាល់អ្នកវាយតម្លៃសមត្ថភាពក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៃព្រះរាជាណាចក្រកម្ពុជា។

ប្រការ២.-

ប្រកាសនេះមានគោលដៅ ៖

- កំណត់អំពីលក្ខណវិនិច្ឆ័យសម្រាប់ការចុះបញ្ជិកាទទួលស្គាល់អ្នកវាយតម្លៃសមត្ថភាព
- ផ្តល់ឱកាសដល់អ្នកសិក្សា អ្នកបច្ចេកទេស និងសាធារណជន មានសិទ្ធិស្នើសុំចុះបញ្ជិកាទទួលស្គាល់អ្នកវាយតម្លៃសមត្ថភាព
- បង្កើតប្រព័ន្ធទិន្នន័យជាតិចុះបញ្ជិកាទទួលស្គាល់អ្នកវាយតម្លៃសមត្ថភាព
- កំណត់អំពីតួនាទីភារកិច្ច និងការទទួលខុសត្រូវរបស់អ្នកវាយតម្លៃសមត្ថភាព។

ប្រការ៣.-

ប្រកាសនេះមានវិសាលភាពគ្របដណ្តប់លើការអនុវត្តដំណើរការវាយតម្លៃ និងចុះបញ្ជិកាទទួលស្គាល់អ្នកវាយតម្លៃសមត្ថភាពនៅព្រះរាជាណាចក្រកម្ពុជា។

ប្រការ៤.-

ខ្លឹមសារលម្អិតនៃលក្ខណវិនិច្ឆ័យក្នុងការកំណត់ និងការចុះបញ្ជិកាទទួលស្គាល់អ្នកវាយតម្លៃសមត្ថភាព ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

ប្រការ៥.-

អ្នកសិក្សា អ្នកបច្ចេកទេស និងសាធារណជន ដែលបានកំពុងផ្តល់ការបណ្តុះបណ្តាលក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឬកំពុងបំពេញការងារលើជំនាញបច្ចេកទេស ឬអាជីព មានសិទ្ធិស្នើសុំចុះបញ្ជិកាទទួលស្គាល់ជាអ្នកវាយតម្លៃសមត្ថភាពស្របតាមលក្ខខណ្ឌតម្រូវ ។

អ្នកវាយតម្លៃសមត្ថភាព អាចមានអាជ្ញាប័ណ្ណមួយឬច្រើន លើមុខរបរណាមួយឬផ្នែកណាមួយនៃមុខរបរ ឬអាជីពជាក់ស្តែងរបស់ខ្លួន។

ប្រការ៦.-

អង្គភាពមានសមត្ថកិច្ចមានសិទ្ធិផ្អាក ព្យួរ ឬដកហូតអាជ្ញាប័ណ្ណលើមុខរបរណាមួយ ឬផ្នែកណាមួយនៃមុខរបរ ពីអ្នកវាយតម្លៃសមត្ថភាពដែលមានចុះបញ្ជិកាទទួលស្គាល់ ក្នុងករណីអ្នកវាយតម្លៃសមត្ថភាពនោះបានប្រព្រឹត្តផ្ទុយពីវិធានធានាគុណភាពជាធរមាន។

Kh

អ្នកវាយតម្លៃសមត្ថភាពដែលត្រូវបានដកហូតអាជ្ញាប័ណ្ណនោះ មានសិទ្ធិស្នើសុំចុះបញ្ជិកាទទួលស្គាល់ជាអ្នកវាយតម្លៃសមត្ថភាពឡើងវិញ។

ប្រការ៧ ..

ការគ្រប់គ្រង ការអនុវត្ត និងការកែលម្អលក្ខណវិនិច្ឆ័យក្នុងការកំណត់ និងចុះបញ្ជិកាទទួលស្គាល់អ្នកវាយតម្លៃសមត្ថភាពក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិបណ្តុះបណ្តាល ឬអង្គភាពទទួលសិទ្ធិ។

អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល មានតួនាទីសម្របសម្រួល និងរៀបចំការងារនេះ។

ប្រការ៨ ..

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៩ ..

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គាធិការនៃអគ្គាធិការដ្ឋានគ្រប់អង្គភាពក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងប្រធានអង្គភាពពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៧រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែមីនា ឆ្នាំ២០២១

រដ្ឋមន្ត្រី

និងជាប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល

អ៊ិត សំហេង

កន្លែងទទួល៖

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិបណ្តុះបណ្តាល
- គណៈកម្មការស្តង់ដាជាតិសមត្ថភាព និងធ្វើតេស្ត
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
  "ដើម្បីជូនជ្រាប"
- រដ្ឋបាលរាជធានី-ខេត្ត
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ